**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់មេត្តាជ្រាបថា **ឧបាសក សោម វ៉ែង** ដែលត្រូវជាឪពុកបង្កើតរបស់ លោក សោម សាវែត ប្រធាននាយកដ្ឋានរដ្ឋបាល និងសរុប នៃក្រសួងមុខងារសាធារណៈ បានទទួលមរណភាពនៅថ្ងៃអាទិត្យ ៦កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ០៧:៣០នាទីសៀល ក្នុងជន្មាយុ៨៤ឆ្នាំ ដោយរោគាពាធ។

**ឯកឧត្តម សយ រតន:** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហ៊ុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នឹងដឹកនាំប្រតិភូអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ២:០០នាទីរសៀល នៅគេហដ្ឋានលេខ១១២ ផ្លូវបេតុង ភូមិទួលតាចាន់ សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាជ្រាបជាព័ត៌មាន និងចូលរួមរំលែកទុក្ខ ព្រមទាំងចាប់មគ្គផលតាមសទ្ធាជ្រះថ្លារៀងៗខ្លួន។

**លោក សោម សាវែត "Som Saveth"** មានគណនី ABA Bank ៖ 017494343 (ដុល្លារ)
001458775 (ខ្មែររៀល)

ថ្ងៃចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សាររំលែកមរណទុក្ខ

## ជូនចំពោះ

## លោក សោម សាវេត ប្រធាននាយកដ្ឋានរដ្ឋបាល និងសរុប ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ ឧបាសក សោម វែង

**លោកប្រធាន ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អានដ៏ជ្រាលជ្រៅ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីក្តុកក្តួល និងសោកស្តាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា **ឧបាសក សោម វែង** ដែលត្រូវជាឪពុកបង្កើតរបស់លោក **សោម សាវេត** ប្រធាននាយកដ្ឋានរដ្ឋបាល និងសរុប បានទទួលមរណភាព នៅថ្ងៃអាទិត្យ ៦កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ០២:៣០ នាទីរសៀល ក្នុងជន្មាយុ ៨៤ឆ្នាំ ដោយរោគាពាធ ។

ស្ថិតក្នុងវេលាដ៏សោកសង្រេង និងក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្តែងនូវសេចក្តីសោកស្តាយ ស្រណោះ អាឡោះអាល័យបំផុត ជាមួយ **លោក សោម សាវេត ព្រមទាំងក្រុមគ្រួសារ** ចំពោះការបាត់បង់ **ឧបាសក សោម វែង** ដែលត្រូវជាឪពុក និងជាជីតាប្រកបដោយព្រហ្មវិហារធម៌មិនចេះរីងស្ងួត និងសង្គហធម៌ដ៏ល្អប្រពៃរបស់ក្រុមគ្រួសារ។

យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែកទុក្ខដោយសេចក្តីសោកសង្រេងបំផុតជាមួយ **លោក សោម សាវេត ព្រមទាំងក្រុមគ្រួសារ** និងសូមសម្តែងនូវការគោរពចំពោះដួងវិញ្ញាណក្ខន្ធរបស់ **ឧបាសក សោម វែង** សូមលោកបានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោក សោម សាវេត ព្រមទាំងក្រុមគ្រួសារ** ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ៕

ថ្ងៃ ចន្ទ ៧ កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ហ៊ុន ស៊ុខា

ផ្លូវវេត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh